ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៥១៩ ក្រ៩ (យ)

ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

-សំណុំរឿងព្រហ្មទណ្ឌលេខ ១២៦
ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ ០៩១
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ១២០៥
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ០២ និង ៣០ នាទីរសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **១២៦** ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] តៃវ៉ាន់ ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ១៥Z ផ្លូវលេខ ១៨៧ ភូមិ៧ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ [redacted] ណាវី (រស់) ម្តាយឈ្មោះ [redacted] វណ្ណៈ (រស់) ទោសពីមុន(គ្មាន)។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦៣ (ក) ដ.ឃ.ដ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ (PJ)។

ដោយមានលោកមេធាវី [redacted] អត្ត [redacted] ជាមេធាវីនៃក្រុមមេធាវីកម្ពុជា សហប្រតិបត្តិការអន្តរជាតិ មានទីតាំងស្ថិតនៅអគារលេខ ៤៥៣៥ ផ្លូវ១០០៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តៃវ៉ាន់។

២.ឈ្មោះ [redacted] រតនៈបញ្ញាសិទ្ធ ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣៧១ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ [redacted] ច័ន្ទ តារា (រស់) ម្តាយឈ្មោះ [redacted] ច័ន្ទកញ្ញាណាកា (រស់) ទោសពីមុន(គ្មាន)។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៦៤ (ក) ដ.ឃ.ដ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ (PJ)។

ដោយមានលោកមេធាវី [redacted] ជាមេធាវីនៃការិយាល័យមេធាវី **អេចអែនអេចប្រាដឺ** មានការិយាល័យ នៅជាន់ទី១ អាគារលេខ១៦សេ១ មហាវិថីម៉ៅសេទុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]**រតនៈបញ្ញាសិទ្ធ**។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៥ និង ៣០ នាទី ឈ្មោះ [redacted] **តៃវ៉ាន់** បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ផ្លាកលេខ**ភ្នំពេញ** 1BI-1074 ឌុបឈ្មោះ [redacted]**រតនៈបញ្ញាសិទ្ធ** មកដល់ចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ បានធ្វើសកម្មភាពឆក់កាបូបយួរដៃ ពណ៌ស្ពែ របស់ជនរងគ្រោះ ភេទស្រី (មិនស្គាល់អត្តសញ្ញាណ) បានសម្រេច រួចជិះម៉ូតូគេចខ្លួន ភ្លាមៗជនរងគ្រោះស្រែកថាចោរៗ ស្របពេលកម្លាំងសមត្ថកិច្ចជំនាញការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល កំពុងល្បាតការពារសន្តិសុខនៅក្បែរនោះ បានជិះម៉ូតូដេញតាម រហូតមកដល់ចំណុចកោសដូង ផ្លូវ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ូតូរបស់ឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតនៈបញ្ញាសិទ្ធ** ដួល ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានទាំងពីរនាក់ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-**បានឃើញ** របាយការណ៍សំយោគលេខ **០៧/២០២០** រ.ប.ក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ **៧៨៨ អ.យ.ភ** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១១៤៧ (ក) ដដ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** បានឆ្លើយថា៖ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៥ និង ៣០នាទី ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ស្លាកលេខ**ភ្នំពេញ** 1BI-1074 ឌុបឈ្មោះ [redacted]**រតនៈបញ្ញាសិទ្ធ** បបួលគ្នាធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ លុះពេលពួកខ្លួនជិះមកដល់ចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ បានឃើញស្ត្រីម្នាក់កំពុងជិះម៉ូតូឌុបម៉ាកសេ១០០ កូវ៉ែ កាន់កាបូបពណ៌ស្ពែដាក់លើភ្លៅ ខ្លួនក៏បើកម៉ូតូទៅក្បែរម៉ូតូរបស់ស្ត្រីនោះ ភ្លាមៗឈ្មោះ [redacted] **រតនៈបញ្ញាសិទ្ធ** បានធ្វើសកម្មភាពឆក់កាបូបបានសម្រេច រួចពួកខ្លួនជិះម៉ូតូគេចខ្លួន មកដល់ចំណុចកន្លែងកោសដូង ផ្លូវលេខ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ូតូរបស់ខ្លួនបានដួល ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយកាបូបដែលឆក់បាននោះ ជ្រុះបាត់មិនដឹងនៅកន្លែងណាទេ។ ចំពោះម៉ូតូខាងលើ ជាម៉ូតូដែលខ្លួនបង់រំលោះជាមួយក្រុមហ៊ុនជែកស៍ ហ្វាយណែន ដោយខ្លួនទើបតែកក់ប្រាក់និងបង់បានរយៈពេលមួយខែប៉ុណ្ណោះ។

ជនជាប់ចោទឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** បានឆ្លើយថា៖ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៥ និង ៣០នាទី ឈ្មោះ [redacted] **តៃវ៉ាន់** បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ផ្លាកលេខ **ភ្នំពេញ 1BI-1074** ឌុបខ្លួន ជិះមកដល់ចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ បានឃើញស្ត្រីម្នាក់កំពុងជិះម៉ូតូឌុបម៉ាកសេ១០០ កូរ៉េ កាន់កាបូបពណ៌ស្លេដាក់លើភ្លៅ ឈ្មោះ [redacted] **តៃវ៉ាន់** ក៏បើកម៉ូតូទៅក្បែរម៉ូតូរបស់ស្ត្រីនោះ ភ្លាមៗខ្លួនក៏ធ្វើសកម្មភាពឆក់កាបូបបានសម្រេច រួចពួកខ្លួនជិះម៉ូតូគេចខ្លួនមកដល់ចំណុចកន្លែងកោសដូង ផ្លូវលេខ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ូតូរបស់ពួកខ្លួនបានដួល ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយកាបូបដែលឆក់បាននោះ ជ្រុះបាត់មិនដឹងនៅកន្លែងណាទេ។ ក្រៅពីសកម្មភាពខាងលើ ខ្លួនមិនធ្លាប់បានធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញនោះទេ។

សាក្សីឈ្មោះ [redacted] **ចំរើន** នាយរងផ្នែកការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល បានឆ្លើយថា៖ នៅថ្ងៃកើតហេតុប្រធានការិយាល័យប្រាប់ថា មានករណីឆក់ច្រើន ក៏បានដាក់កម្លាំងល្បាតក្នុងម៉ោងប្រជាពលរដ្ឋចេញរកស៊ី បានប្រទះឃើញជនសង្ស័យពីរនាក់ជិះម៉ូតូយ៉ាងលឿន ក៏កម្លាំងជិះម៉ូតូដេញតាម រួចឃើញម៉ូតូរបស់ជនសង្ស័យដួល ក៏ត្រូវកម្លាំងឃាត់ខ្លួនបានតែម្តង។

សាក្សីឈ្មោះ [redacted] **ចាន់រ៉ា** នាយរងផ្នែកការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនកំពុងជិះម៉ូតូល្បាត ក៏លឺជនរងគ្រោះស្រែកថាចោរៗ ខ្លួនក៏ជិះម៉ូតូដេញតាម រហូតដល់ផ្លូវកោសដូង ម៉ូតូរបស់ជនសង្ស័យជិះគ្នាពីរនាក់ដួល ខ្លួនក៏ចុះពីលើម៉ូតូដេញតាម និងចាក់តាមអាយឌីហៅកម្លាំងចុះមកជួយ ហើយប្រជាពលរដ្ឋនៅក្បែរនោះ ក៏ជួយ រហូតឃាត់ខ្លួនបានជនសង្ស័យទាំងពីរនាក់។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿងឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** បានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះប្រាកដមែន ចម្លើយនេះ ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជនជាប់ចោទនៅគ្រប់ដំណាក់កាល។ ការដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃ មកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយការឆក់តាមផ្លូវសាធារណៈគឺជាអំពើល្អចមានស្ថានទម្ងន់ទោស មានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះតំណាងអយ្យការរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ **៧៨៨ អ.យ.ភ** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទទៅតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមអង្គហេតុ និងចម្លើយសារភាពដោយស្មោះត្រង់របស់កូនក្តីខ្លួន បានទទួលស្គាល់កំហុស និងមានការសោកស្តាយក្រោយយ៉ាងខ្លាំង។ កូនក្តីខ្លួនទើបតែពេញវ័យ ខ្វះការពិចារណាឱ្យបានល្អិតល្អន់ និងកំពុងនៅសិក្សា មានឆន្ទៈចង់កែប្រែខ្លួនមករស់នៅក្នុងសង្គម និងបន្តការសិក្សាឡើងវិញ។ ខ្លួនជាមេធាវីស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់ស្ថានសម្រាលទោស និងបន្ធូរបន្ថយទោសដល់គាត់ផង ដើម្បីអាចឱ្យគាត់ធាប់បានមកបន្តការសិក្សា និងកែប្រែខ្លួនជាមនុស្សល្អក្នុងសង្គមវិញ។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនបានឆ្លើយសារភាពដោយស្មោះត្រង់ជូនតុលាការ ទទួលស្គាល់កំហុសខ្លួនឯង និងមានការសោកស្តាយជាខ្លាំង។ កូនក្តីខ្លួនទើបតែពេញវ័យ ខ្វះការពិចារណាឱ្យបានល្អិតល្អន់ និងកំពុងនៅសិក្សា មានឆន្ទៈចង់កែប្រែខ្លួនមករស់នៅក្នុងសង្គម និងបន្តការសិក្សាឡើងវិញ។ ខ្លួនជាមេធាវីស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់ស្ថានសម្រាលទោស និងបន្ធូរបន្ថយទោសដល់គាត់ផង ដើម្បីអាចឱ្យគាត់ធាប់បានមកបន្តការសិក្សា និងកែប្រែខ្លួនជាមនុស្សល្អក្នុងសង្គមវិញ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** សំណូមពរតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ដើម្បីអាចចូលរៀនធាប់ៗ និងបានជួបជុំគ្រួសារវិញ។

ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ

ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១.កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៥ និង ៣០ នាទី នៅចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ពិតជាមានករណី**លួចមានស្ថានទម្ងន់ទោស** មួយកើតឡើង ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ផ្លាកលេខភ្នំពេញ 1BI-1074 ឧបគ្នាធ្វើសកម្មភាពឆក់កាបូបយួរដៃ ពណ៌ស្ពែ របស់ជនរងគ្រោះ អោទស្រី (មិនស្គាល់អត្តសញ្ញាណ) បានសម្រេចប្រាកដមែន រួចជិះម៉ូតូគេចខ្លួន មកដល់ចំណុចកោសដូង ផ្លូវ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបាន។

២.នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** បានធ្វើឱ្យសារភាពដូចៗគ្នាថា៖ ពួកខ្លួនពិតជាបានជិះម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ២០២០ ពាក់ផ្លាកលេខ**ភ្នំពេញ** 1BI-1074 ឧបគ្នាធ្វើសកម្មភាពឆក់កាបូបយួរដៃ ពណ៌ស្ពែ របស់ជនរងគ្រោះ អោទស្រី (មិនស្គាល់អត្តសញ្ញាណ) បានសម្រេចប្រាកដមែន តែត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបាន ពេលពួកខ្លួនជិះម៉ូតូដួលនៅចំណុចកោសដូង ផ្លូវ២៣០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដែលចម្លើយរបស់ជនជាប់ចោទនាពេលនេះ បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់ខ្លួននៅគ្រប់ដំណាក់កាល ស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សីជាកម្លាំងសមត្ថកិច្ចចុះបង្ក្រាប និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងសំណុំរឿង អាចបញ្ជាក់ឱ្យតុលាការជឿជាក់បានថា៖ ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** និងឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស** ដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៣.តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំខាងលើឃើញថា៖ មានមូលហេតុគ្រប់គ្រាន់ និងស្របតាមច្បាប់ ដែលតុលាការគប្បីលើកយកមកពិចារណា និងសម្រេចបាន។

៤.តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើឃើញថា៖ មានហេតុផលសមរម្យដែលតុលាការគួរគប្បីលើកយកមកពិចារណាបាន។

៥.ជារួម ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់សាក្សី របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ព្រមទាំងភស្តុតាងពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងសំណុំរឿង អាចឱ្យតុលាការមានមូលដ្ឋានគ្រប់គ្រាន់និងជឿជាក់ថា៖ ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted]**រតន:បញ្ញាសិទ្ធ** ភេទប្រុស អាយុ ១៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស** នៅចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងពីរនាក់ បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គមព្រមទាំងទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលច្បាប់បានហាមឃាត់និងការពារជាដាច់ខាត។

៧.ជនជាប់ចោទជានីតិជន មានស្មារតីគ្រប់គ្រាន់ បានប្រព្រឹត្តបទល្មើសដោយដឹងខុសត្រូវ។

៨.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ និងឈ្មោះ [redacted]**រតន:បញ្ញាសិទ្ធ** ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

៩.ជនជាប់ចោទទាំងពីរនាក់ រៀនសូត្របានតិចតួច ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង និងបានឆ្លើយសារភាពដោយស្មោះត្រង់ជូនតុលាការនូវអំពើប្រព្រឹត្តខ្លួន ដែលតុលាការគប្បីពិចារណាលើស្ថានភាពនេះ ដើម្បីកំណត់អំពីកម្រិតទណ្ឌកម្មលើជនជាប់ចោទ។

១០.តាមការពិនិត្យហេតុផលនៃពាក្យសុំចលនវត្ថុត្រឡប់មកវិញ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] **សុខគីម** ជាតំណាងឱ្យក្រុមហ៊ុនហិរញ្ញវត្ថុ ជែកស៍ ហ្វាយណែន (ខេមបូឌា) ម.ក រួមទាំងឯកសារភ្ជាប់មកជាមួយនិងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** អាចបញ្ជាក់ច្បាស់លាស់ថា៖ ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០២០ ពណ៌ខ្មៅ ពាក់ផ្លាកលេខ**ភ្នំពេញ** 1BI-1074 គឺពិតជាម៉ូតូរបស់ក្រុមហ៊ុនហិរញ្ញវត្ថុ ជែកស៍ហ្វាយណែន (ខេមបូឌា)ម.ក ដែលជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** ទើបតែបង់រំលស់ជាមួយក្រុមហ៊ុនបានរយៈពេលមួយខែប្រាកដមែន ចំណុចនេះសរបញ្ជាក់យ៉ាងច្បាស់ថា ម៉ូតូមួយគ្រឿងខាងលើ ពុំមែនជាកម្មសិទ្ធិរបស់ជនជាប់ចោទឈ្មោះ [redacted] **តៃវ៉ាន់** នោះទេ។ ដូច្នេះ ដើម្បីជៀងវាងផលប៉ះពាល់ដល់ក្រុមហ៊ុន ក៏ដូចជាជីវភាពរបស់ជនជាប់ចោទ ក្រោយពីបានអនុវត្តទោសចប់ តុលាការគប្បីសម្រេចប្រគល់ម៉ូតូមួយគ្រឿងខាងលើ ឱ្យទៅឈ្មោះ [redacted] **សុខគីម** ជាតំណាងក្រុមហ៊ុនហិរញ្ញវត្ថុ ជែកស៍ហ្វាយណែន (ខេម បូឌា) ម.ក ជាម្ចាស់ដើមវិញ។

១១.វត្ថុចាប់យកមាន៖ ម៉ូតូចំនួនមួយគ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ លេខតួនិងលេខម៉ាស៊ីន ៥៦៤០៧៣១ ពាក់ផ្លាកលេខ **ភ្នំពេញ** 1IB-1074 ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ **០៧២ រ.ន.ត** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ **គប្បីសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមវិញ**។

<u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោសលើ៖

ក.ឈ្មោះ [redacted] **តែន៉ាន់** ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ

ខ.ឈ្មោះ [redacted] **រតន:បញ្ញាសិទ្ធ** ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ៥(ប្រាំ)ឆ្នាំ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះលក់ផ្កា ផ្លូវលេខ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ តាមប្បញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

២.វត្ថុចាប់យកមាន៖ ម៉ូតូចំនួនមួយគ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ លេខតួនិងលេខម៉ាស៊ីន **៥៦៤០៧៣១** ពាក់ផ្លាកលេខ **ភ្នំពេញ 1IB-1074** ត្រូវប្រគល់ឱ្យទៅឈ្មោះ [redacted] **សុខគីម** ជាម្ចាស់ដើមវិញ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]**តែវ៉ាន់** ឈ្មោះ [redacted]**រតន:បញ្ញាសិទ្ធ** និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ	**ក្រុមប្រឹក្សាជំនុំជម្រះ**	**ក្រុមប្រឹក្សាជំនុំជម្រះ**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned with CamScanner